បន្ទាប់ពីនោះ គឺនាងបានឮសំឡេងភ្លេងពិនពេញមួយរសៀលរហូតដល់មេឃងងឹត។

ពេលដែលស៊ីនយុនកំពុងរៀបចំក្រណាត់សូត្រនៅក្នុងបន្ទប់សម្ភារៈ អ្នកស្រីទៀងបានបង្ហាញខ្លួនជាមួយថាសមួយទៀត ដែលមានបាយមួយកូនចាន និងមីស៊ុបពេញមួយចានធំ។

«ឯងគ្មានបាយព្រឹក មានតែនំប៉ាវបី តើឯងខឹងទេ?»

គាត់សួរដូច្នេះដោយគ្មានស្នាមញញឹមទេ។ ប៉ុន្តែស៊ីនយុនជាអ្នកអត់ធ្មត់តាំងពីកំណើតមក នាងញញឹមហើយនិយាយថា សូម្បីនំបីនោះសម្រាប់បីពេលក៏ជាព្រះគុណនៃព្រះនាងពិតៗ។

អ្នកស្រីទៀងសម្លឹងនាងដោយកន្ទុយភ្នែករួចចាកចេញ។ នាងថយមកហូបស៊ុបភ្លាមព្រោះពោះឃ្លានណាស់ មេឃរងាខ្លាំង។ នៅមុខបន្ទប់ កំពុងត្រៀមមាត់យ៉ាងសប្បាយស្រាប់តែ...

«ស៊ីនយុន យើងឃ្លានខ្លាំងណាស់!»

នាងងាកមកភ្លាមព្រោះមិនមែនឮតាមខ្យល់ទេ វាច្បាស់នឹងត្រចៀកពេក។ ស្តាប់យូរៗទៅដូចជាសំឡេងមិត្តរបស់នាង មុីហ្វួងដូច្នេះ។ ស្រីតូចប្រញាប់ដាក់ចានចុះ ព្រោះនឹកឃើញហើយពីរឿងដំណាក់ខាងត្បូងនេះ ហើយដែលអ្នកង៉ានហានបានប្រាប់ថា ជាកន្លែងដែលមុីហ្វួងទៅចុះហេតុអ្វីម្សិលមិញយើងភ្លេចសួរនាំគាត់?

ស៊ីនយុនគិតហើយក្រោកឡើងរំពៃរត់រកផង ស្រែកហៅតិចៗផង៖

«មុីហ្វួង ឯងមែនទេ? ឯងឃើញខ្ញុំមែនទេ?!»

គ្មានការឆ្លើយឆ្លង។ ពេលស៊ីនយុនងាកមកក៏មិនឃើញមានអ្នកណាទាំងអស់ តាមពិតជាសំឡេងនៃអារម្មណ៍ដែលនឹកមិត្ត។ ស៊ីនយុនគិតដូច្នេះ ហើយក៏ចាប់ចានមកហូប តែបានមួយម៉ាត់មិនទាន់នាងស្រក់ទឹកភ្នែកយំ។

នាងនិយាយតិចៗម្នាក់ឯងថា ជីវិតនេះឯកាណាស់ មានមិត្តម្នាក់ក៏មិនដឹងទៅដល់ទីណា? មិនយូរនាងចាក់ស៊ុបមីកន្លះចានទៅលើដីហើយផ្សងថា សូមឱ្យអ្នកណាក្តីចង់បានស៊ុបនេះហូបក៏ហូបចុះ តែត្រូវឧទ្ទិសទៅដល់មិត្តនាងឱ្យបានអាហារបីពេលនិងភួយដណ្តប់។

ពេលយប់មកដល់ ស៊ីនយុននាងចូលសម្រាកទាំងពោះឆ្អែតនិងមិនហត់នឿយខ្លាំងដូចនៅឯដំណាក់អ្នកបម្រើទេ។

ធម្មតាកាលពីនៅឯដំណាក់អ្នកបម្រើ ជារៀងរាល់ពេលយប់នាងតែងតែត្រូវគេប្រើឱ្យទៅគក់ច្របាច់ដល់អ្នកស្រីង៉ាវហាន រហូតដល់ម្ចាស់ដំណាក់លង់លក់ ប៉ុន្តែរហូតដល់ពេលនេះនាងយល់ថា នៅដំណាក់ថ្មីមិនសូវមានការងារសោះ។

ប្រហែលនាងជាខ្ញុំបម្រើឋានៈតូចពេក មិនមានសិទ្ធិអ្វីទៅប៉ះពាល់រាងកាយនៃព្រះនាងមកពីនគរឆ្ងាយនោះទេ។

ស៊ីនយុន នាងគេងគងថ្ងាសគិតបណ្ដើរនឹកអផ្សុកបណ្ដើរថា ពេលវេលានៅទីនេះដូចជាសល់ច្រើនហើយមិនសូវបានជាប្រយោជន៍អ្វី ប្រសិនជាបានមិត្តរបស់នាងមកម្នាក់ទៀត ប្រហែលជាសប្បាយខ្លាំងគ្រាន់នឹងបានគេជជែកគ្នាអំពីរឿងអ្វីៗទាំងអស់ដែលគួរឱ្យងឿងឆ្ងល់នៅក្នុងរាជវាំង។

តុកតុកតុក

មានគេមកគោះទ្វារ ស៊ីនយុនស្ទុះអង្គុយ។ យប់ជ្រៅហើយ តើអ្នកណាមានការអ្វី?

«ស៊ីនយុនគឺយើង!»

ជាសំឡេងរបស់អ្នកស្រីទៀង។ ដឹងហើយថាអ្នកណាមករក ស៊ីនយុនស្ទុះទៅបើកទ្វារឱ្យគាត់។ ស្ត្រីចំណាស់ចូលមកក៏ក្រឡេកមើលជុំវិញបន្ទប់ឃើញថាអ្វីៗដូចប្រក្រតីហើយគាត់ក៏សួរនាងថា៖

«ឯងមិនពន្លត់ទៀនទេពេលគេង?»

«ខ្ញុំមិនហ៊ានទេព្រោះងងឹតខ្លាំងពេក!»

«មិនអីទេ វាគង់តែរលត់នៅពេលដែលវាអស់! ហើយថ្ងៃនេះយើងមានរបស់ខ្លះចង់ឱ្យឯងធ្វើទាំងយប់!»

«ចាស៎ ខ្ញុំកំពុងតែទំនេរ!»

គាត់សម្លឹងមុខនាង ឃើញថាមិនបានធ្វើពុតក៏បានលាកញ្ចប់បង្វេចដែលស្ពាយមក។ ក្នុងនោះមានឫសឈើ មើមឈើជាច្រើនប្រភេទក្រៀមក្រញ៉ង់និងមានក្លិនខុសៗគ្នា។ មិនតែប៉ុណ្ណោះក៏មានជាកូនត្បាល់តូចមួយ ធ្វើអំពីថ្មប៉ុនបាតដៃរបស់ស៊ីនយុន។

សូម្បីតែកូនអង្រែក៏គាត់យកមកដែរ។ ស៊ីនយុនដឹងថាជារបស់បុកថ្នាំឫស។ ស្ត្រីនោះបង្គាប់នាងឡើងថា៖

«ឯងត្រូវបុកវាឱ្យល្អ បុកវាបញ្ចូលគ្នាទាំងអស់ ហើយទុកក្នុងប្រអប់មួយនេះឱ្យប្រយ័ត្នប្រយែងបំផុត កុំឱ្យថ្លោះធ្លោយមានដីធូលីលាយឡំ!»

«ចាសខ្ញុំអាចធ្វើបាន!»

«ល្អហើយ! ពេលធ្វើការងារចប់ ឯងទុកវានៅលើតុនេះហើយចូលសម្រាក! មួយវិញទៀត យប់នេះ ព្រះនាងប្រហែលជាមានដំណើរទស្សនាផ្កាព្រិលក្នុងសួន ទ្រង់មិនចង់ឱ្យមានអ្នកណាទៅរំខាននោះទេ! ហាមឯងចេញពីបន្ទប់ បើមានៈនោះ ប្រយ័ត្នមានទោស!»

«ចាស៎!»

ទោះបីមានមាត់ស៊ីនយុនឆ្លើយបែបនេះ ប៉ុន្តែក្នុងចិត្តទៀតសោតមានប្រធានបទត្រូវគិតឆ្ងល់បន្ថែម។ នាងនឹកឃើញដល់រឿងជាច្រើនធ្លាប់ឮចាស់ៗនិទាន។ ព្រះនាងក្នុងស្រទាប់ផ្កាព្រិលរាំផង ផ្លុំខ្លុយផងពិតជាគួរឱ្យចង់ឃើញបំផុត។

នាងចាប់ផ្ដើមលាឫសឈើរើសយកមកបុក។ ក្លិនម្យ៉ាងដែលនាងធុំនៅផ្ទះបាយ បានធ្វើឱ្យស្រីបម្រើនឹកឃើញឡើងវិញពីភាពលាក់លៀមរបស់អ្នកបម្រើវ័យចាស់។

តើព្រះនាងរូបស្អាតយ៉ាងណាទៅ គាត់មិនដែលឃើញផ្កាព្រិលទេឬក៏យ៉ាងម៉េច ឬមួយថានៅភាគខាងជើងមិនដែលមានធ្លាក់ព្រិលទេ?

ហើយគាត់អប់ស្បែកនឹងឫសឈើទាំងនេះឬអ្វី ហេតុអីបានជាមិនចង់ឱ្យមានអ្នកហែហម? គាត់មានតែអ្នកបម្រើតែពីរនាក់ ប្រុសមួយស្រីមួយ ហេតុអីបែរជាស្ងប់ស្ងាត់ម្ល៉េះ?

ភ្លាមនោះនាងនឹកឃើញពីភាពឯកោរបស់ខ្លួនក៏សួរឡើង៖

«អុះមីង ខ្ញុំមានមិត្តម្នាក់ឈ្មោះម៉ីហ្សួង ខ្ញុំឮថាគេត្រូវបញ្ជូនមកដំណាក់ខាងត្បូងនេះ តើមីងមានដែលដឹងដំណឹងគេទេ!»

«ឯងសួរយើងដូច្នេះឱ្យយើងសួរអ្នកណា? នៅទីនេះមានតែយើងបួននាក់ ឯងទៅរកមនុស្សផ្សេងពីណាមក?! ធ្វើការងារឱ្យរហ័សទៅ! អី គេមិនមែនបុកអីចឹងទេ គេធ្វើធ្ងន់ៗបែបនេះ!»

អ្នកបម្រើជំនិតនៃព្រះនាង ដូចជាចង់តែគេចវេះមិនចង់ឆ្លើយជាមួយស៊ីនយុនសោះ តែនាងនៅតែមានភាពឆោតល្ងង់។

«ព្រោះខ្ញុំធ្លាប់ឮមនុស្សយំ»

«មនុស្សយំពីណាមក?!»

«ចេញពីអណ្ដូងនុះ!»

នាងប្រុងចោលត្បាល់បុកក្រោកទៅបង្អួចតែត្រូវគាត់ស្រែកកាត់ថា៖

«ផ្ដាសហើយឯង! ឈប់រវល់រវើរវាយឆាប់ធ្វើការងារ!»

គាត់ថាហើយក៏ដើរចោលនាងបាត់ទៅ ធ្វើបិទទ្វារពីក្រៅឱ្យទៀត។

ស៊ីនយុនក៏ចាប់ផ្ដើមការងារបុកថ្នាំរបស់នាង។ កាន់តែបុក នាងកាន់តែធួលក្លិនវាពេលធួលហួសហេតុដល់ត្រូវកណ្ដាស់ញាប់ៗ ក៏សម្រេចចិត្តបង្ហើបបង្អួចតិចៗឱ្យក្លិនខ្យល់ថ្មីចេញចូល។

នាងអង្គុយបុកឫសឈើបែបនេះ រហូតដល់ចប់សព្វគ្រប់ទើបយល់ថា ស្វាបឡើងៗដោយហត់នឿយខ្លាំង ទើបចូលទៅប្រះដណ្ដាប់ភួយសំងំដេក។

ដោយភួយដ៏កក់ក្ដៅនិងក្រពះឆ្អែតនាងលក់ភ្លឹងភ្លេចរឿងខ្យល់ត្រជាក់ជ្រៀតចូលមកតាមបង្អួចដែលចំហ។

ស្រាប់តែមិនបានប៉ុន្មាន ឮសំឡេងចម្លែកបានដាស់នាងសើងមើង។ បើកភ្នែកមកក៏បិទទៅវិញព្រោះងោកងុយ ស្រាប់តែមួយក្រឡេកនោះស៊ីនយុនឃើញស្រមោលមនុស្សរត់ជាជួរតាមប្រឡបង្អួចដែលខ្លួនបង្ហើប។ ដោយមិនដឹងខ្លួននាងស្ទុះក្រោកអង្គុយ។

ចោរមែនទេ?

វិមាននេះមានតែមនុស្សបីនាក់ បួនទាំងនាងនេះហើយ បានមនុស្សទាំងជួរពីណាមកឬមួយក៏ជាចោរ? ស្រីបម្រើអើតតាមប្រលោះនោះ បាត់ពួកគេស្ងាត់សូន្យ។ ងាកមកតុបុកថ្នាំសល់តែត្បាល់ទទេ ចំណែកដន្លាប់ដែលផ្ទុកល្បាយមិនដឹងអ្នកណាចូលមកពីថ្មើរណាយកវាទៅណាបាត់អស់ទៅហើយ។

ដោយភ័យភាំង ស៊ីនយុនក្រោកចាកចេញពីបន្ទប់តាមរកសួរនាំស្ត្រីឈ្មោះទៀងក្រែងលោជាគាត់ដែលចូលមកប្រមូលទៅ។ នាងចេញយឺតៗទោះជាអារម្មណ៍ជាប់ខ្លួនមកថា ច្បាស់ជាមានទោសបើឱ្យគេប្រទះឃើញ។

ម្យ៉ាងគិតថា ណ្ហើយគេកំដរព្រះនាងគេទៅមើលផ្កាព្រិលអស់ទៅហើយ មានអ្នកណាមករវល់នឹងនាងទៅ? ភ្លាមនោះ នាងឈានចេញដល់ប្រាសាទធំ បែរជាមានអារម្មណ៍ថា ទីនេះងងឹតណាស់មិនដូចនាងគិតពីប្រណីតភាពដោយភ្លើងពណ៌មាសភ្លឺរន្ទាលកាលពីថ្ងៃនោះទេ។ មានអារម្មណ៍ថាគ្រប់យ៉ាងចាស់ ទ្រុឌទ្រោមខ្លាំងនិងមានក្លិនសំណើម ធូលី ស្លែ សំបុកសត្វកខ្វក់ខុសពីកាលដែលមកដល់ពីម្សិល។

ដោយមានខ្យល់ត្រជាក់ស្រៀវផង ស៊ីនយុនភ័យព្រោះមិនអាចមើលអ្វីឃើញច្បាស់ ក៏សម្រេចបកមកយកភ្លើងទៀនពីក្នុងបន្ទប់។

ទើបនឹងប៉ះដល់ដើមទៀន ស្រាប់តែឮសំឡេងខ្សឹប៖

«ស៊ីនយុន ឯងឆាប់ចាកចេញពីទីនេះទៅ!»

សំឡេងនេះមកឮក្បែរត្រចៀកមួយរំពេច ដូចជាមកខ្សឹបប្រាប់នាងតាមខ្យល់កាលពីល្ងាចដែររកតែស៊ីនយុនងាកមកក៏មិនឃើញមានអ្នកណាទាំងអស់។

«ម៉ីហួងឯងនៅក្បែរៗនេះមែនទេ?!»

ស៊ីនយុននិយាយម្នាក់ឯងទាំងបែកញើសសើមស្អិតដៃ។ នាងភ័យណាស់បានជាបែកញើសទាំងមេឃធ្លាក់ព្រិលតែនាងខំដើរលបមកកណ្ដាលប្រាសាទគិតថា ម៉ីហួងអាចនឹងត្រូវជាប់ឃុំនៅបន្ទប់សម្ងាត់ណាមួយក្នុងប្រសាទដ៏ធំនេះ។

រឹតតែភ័យបំផុតគឺបំបែរទៀនមកក៏ឃើញមនុស្សប្រុសម្នាក់ដែលជាអាមាត្យរបស់ព្រះនាងនៅភាគខាងត្បូងកំពុងតែនៅឈរចំពីមុខមិនដល់បីជំហានពីគ្នា លើដៃមានកាន់កាំបិតផ្គាក់សស្វាចមួយ។

ភ្នែកឈរសម្លក់មករបស់ជននេះ ធ្វើឱ្យស៊ីនយុនភ្ញាក់ភ័យធ្លាក់ទៀនពីដៃរលត់ឈឹប។ ភ្លាមៗនោះហើយដែលនាងស្រែកដោយភ័យរន្ធត់ ហើយសន្លប់លែងដឹងខ្លួនក្រោយឮសំឡេងខ្យល់ស្ទុះលើកកាំបិតសំពងមកខ្លួននាង។

ពេលដែលមានដឹងខ្លួនឡើងវិញ ក៏ឃើញខ្លួនឯងគេងនៅលើគ្រែ ហាក់បីដូចជារឿងកាលយប់មិញគឺជារឿងយល់សប្តិ។ ស៊ីនយុនក្រោកឡើងចួនជាមួយស្នូរគោះទ្វារយ៉ាងរន្ថើន ដោយមកជាមួយសំឡេងខឹងសម្បារបស់អ្នកស្រីទៀងដែលសួរឡើងថា៖

«ស៊ីនយុន ឯងដេកដើរថ្មើរណាភ្ញាក់ បានជាមិនឃើញមានបោសជូតសម្អាតព្រះរាជដំណាក់?!»

ឮហើយកាលណា អ្នកបម្រើតូចស៊ីនយុនស្ទុះស្ទាងើបឡើងមកបើកទ្វារហើយសួរ៖

«មីង មីងចូលមកយកថ្នាំទៅមែនទេ?!»

អ្នកស្រីទៀងម្នាក់នេះ មិនតបឆ្លើយអ្វី តែគាត់ក្រឡេកមកមើលតុ។ ដើមទៀនដែលនាងបានកាន់យកចេញក៏នៅទីនោះ ដន្លាប់ថ្នាំក៏នៅទីនោះ។ ស៊ីនយុនសឹងផ្ងារក្រោយ នាងចំហមាត់។ ចិត្តស៊ីនយុនចង់តវ៉ាថា ចេញទៅក្រៅកាលពីយប់មិញ គឺកាន់ចេញទៅមែន ថែមទាំងរបូតដៃពេលពើបនឹងជនមុខកាចៗ ម្តេចអាចមកនៅបញ្ឈរលើតុដដែលបាន?

«ឯងឈឺ?!»

«អត់ទេមីង!»

«អ៊ីចឹងចេញមកធ្វើការ!»

ថាចប់គាត់ប្រមូលដន្លាប់នឹងត្បាល់គ្រប់យ៉ាងចេញមកវិញ។ មកដល់ខាងក្រៅ ស៊ីនយុនមិនមាត់មិនកមិននិយាយរឿងពិតដែលក្រោយមកក្លាយជាសុបិននោះទៀតទេ ខ្លាចក្រែងស្ត្រីឈ្មោះទៀងទៅទូលព្រះនាងថានាងជាក្មេងមានបញ្ហាស្មារតី។ ស៊ីនយុនចាប់យកធុងឈើហើយនិងកំណាត់ ដើរទៅក្បែរអណ្តូងប្រុងដងទឹក ស្រាប់តែឮសំឡេងមនុស្សប្រុសគួរឱ្យខ្លាចស្រែកសម្លុត៖

«ឯងឆាប់ត្រលប់មកវិញ!»

ស្រីបម្រើបែរមកវិញឃើញមនុស្សមុខមាំជាអាមាត្រកាន់ផ្គាក់ ដែលនាងយល់សប្តិឃើញកាលពីយប់មិញនៅឈរកាន់ដាវវែងមួយ ហើយធ្វើមុខកំណាចមែន។

«អណ្តូងនេះគ្មានទឹក ឯងមិនឮនិយាយទេ? អណ្តូងនៅខាងនោះ»

ដូច្នេះនាងក៏លបលួចមើលទៅអណ្តូងបុរាណដ៏ធំមួយនោះជាចុងក្រោយ ហើយទើបបែរដើរទៅតាមទិសដៅដែលអាមាត្យសែនកាចបានចង្អុលដៃឱ្យនាង។

ស៊ីនយុនក៏ទៅដងទឹកហើយយកមកជូតដំណាក់ទាំងអារម្មណ៍មិនជ្រះស្រឡះទេ។ កំពុងតែជូតសម្អាតស៊ីនយុនងាកមកប្រទះឃើញតំណក់ទៀននៅសល់ខ្លះនៅតាមផ្លូវដែលនាងចេញពីបន្ទប់មក។

បើគ្រប់យ៉ាងកាលពីយប់មិញជាសុបិនម្ដេចក៏មានតំណក់ទៀននៅសល់ទីនេះ?

វាសមតែយប់មិញខ្លួនពិតជាបានមកដួលសន្លប់នៅទីនេះ?

ពិតជាមានអ្វីមួយធ្វើឱ្យស៊ីនយុន មានអារម្មណ៍មិនសប្បាយចិត្តជាខ្លាំងហើយចង់ដឹងការពិតខ្លាំងឡើងៗ។

ពួកគេទាំងនេះពិតជាមានអ្វីមួយសំខាន់លាក់កំបាំងចំពោះនាង។ រឿងមួយទៀតដែលធ្វើឱ្យស៊ីនយុន មិនអស់ចិត្តគឺហេតុអ្វីបានជាអណ្ដូងនោះត្រូវបានហាមឃាត់មិនឱ្យនាងចូលក្បែរ?

ជាមួយគំនិតទាំងអស់នេះចេះតែមកឆ្កឹះចិត្ត ពេលល្ងាចឡើង នៅពេលដែលស្ត្រីអ្នកបម្រើឈ្មោះទៀង និងអាមាត្រមុខកំណាចកំពុងតែហូបបាយដូចរាល់ដង ស៊ីនយុន តាមលបសម្លឹងពួកគេ។

ដូច្នេះពេលឃើញបានឱកាសកាលណា ស៊ីនយុនក៏រត់យ៉ាងលឿន កាត់តាមសួនច្បារក្រាស់ៗនោះទាំងព្រិលបន្តធ្លាក់ឆ្ពោះទៅអណ្ដូងហើយ ឱនពិនិត្យអណ្ដូងថ្មមៗ។

អណ្ដូងពិតជារចនាបានជាមួយក្បូរក្បាច់យ៉ាងអភិជន។ វាមានដែនកម្ពស់ខ្ពស់ប្រហែលនឹងទ្រូងនាងហើយធ្វើពីថ្មម៉ាបពណ៌សឆ្លាក់ក្បាច់ជាអក្សរចិនបុរាណ ស៊ីនយុនមិនចេះដល់ទេ។

ទោះយ៉ាងណា មានឈ្មោះធំៗនៅចំកណ្ដាលថា អ្នកម្នាងសៀវប្រេកពទឹក។ នេះបានសេចក្ដីថា ជាកម្មសិទ្ធិនៃអ្នកម្នាងដែលត្រូវបានព្រះរាជាសព្វព្រះទ័យពន់ពេកដូចពាក្យអ្នកបរទេះស្ដាយថា មិនសមណានាងមានអាយុខ្លីសោះ។

នាងមានអារម្មណ៍សួរខ្លួនឯងដោយចង់ដឹងទៀតថា តើអណ្ដូងមានទឹកឬស្ងួត ហេតុអីបានជាអាមាត្យនោះហាមឃាត់មិនឱ្យដង?

ដូច្នេះនៅពេលដែលនាងឱនទៅពិនិត្យ ស្រាប់តែឃើញថា ជ្រៅសន្លឹមខ្មៅងងឹតមិនឃើញមានអ្វីទាំងអស់។

មិនអស់ចិត្តជាខ្លាំង នាងខំលោតតោងឡើងពិនិត្យទៀត ក៏ឮសូរសម្រិបជើងជាន់ព្រិលរលាយខ្សាកៗមកពីឆ្ងាយ។

ភ្លាមនោះ នាងបានឃើញអ្នកបម្រើចំណាស់ទៀងដែលតែងតែហាមឃាត់នាងមិនឱ្យដើរហើរដោយសេរីលើកថាសមួយពោរពេញទៅដោយដន្លាប់ដែលនាងស្គាល់និងអ្វីផ្សេងទៀតតម្រង់មក។

នាងលោតចុះស្រាលស្ញើកនឹងថយមកពួនក្រោយរុក្ខជាតិដែលក្រាស់ដោយទឹកកកសក្បុស។

គាត់បានដើរមកដល់ពីមុខស៊ីនយុន ដែលនាងបានលាក់ខ្លួនមិនឱ្យគាត់ឃើញ ប៉ុន្តែនាងអាចមើលឃើញគាត់។ ស្ត្រីឈ្មោះទៀងដាក់ថាសចុះលើមាត់អណ្ដូងហើយបែរបន់។

ភ្លាមនោះនាងឃើញគាត់ជូតទឹកភ្នែករួចស្រែកថា «សូមព្រះនាងសោយ»។

ដោយទ្រូងធីតផតភ័យ ស៊ីនយុនមិនដឹងទេថាហេតុអ្វីបានជាព្រះនាងរបស់គាត់ទៅនៅក្នុងអណ្ដូង? ភ្លាមនោះនាងបានឃើញអណ្ដូងកម្រើករំពើក ផ្សែងបានត្បុលចេញមកពីក្នុងអណ្ដូងក្រាស់ដូចពពកវិល ចំណែកស្ត្រីម្នាក់មានវ័យក្មេងរុំមុខដោយស្បៃបានហោះឡើងមកពីក្នុងនោះជារូបរាងមនុស្សមួយកំណាត់ដែលគ្មានជើងនិងឈរលើផ្សែងបាន។

ស៊ីនយុនដំបូងស្រឡាំងកាំង ក្រោយមកចាប់ផ្ដើមធាក់ថយក្រោយដោយការភ័យខ្លាចព្រោះទាំងអ្នកបម្រើនិងព្រះនាងសុទ្ធតែអាចបណ្ដែតខ្លួនបានដោយមិនមានជើងដើរនោះទេ តើពួកគេតាមពិតគឺជាអ្វី?

សូម្បីតែពេលព្រះនាងទះដៃបីដង ក៏អាមាត្យកំណាចម្នាក់នោះបណ្ដែតខ្លួនមកក្បែរដូចគ្នាដែរ។ ស៊ីនយុនឃើញជនទាំងបីជុំគ្នាចាប់យកម្ហូបលើថាសមកបរិភោគយ៉ាងឆ្ងាញ់។ ស៊ីនយុនទន់ជើងអង្គុយស្រែកមិនរួច មិនយូរប៉ុន្មាននាងឃើញ អាមាត្រចាកចេញ ចំណែកយាយទៀងបានចាប់ផ្ដើមបើកយកដន្លាប់ឫសឈើដែលប្រើនាងឱ្យបុក មកលាបមុខនិងខ្លួនព្រះនាង។ ពេលនោះហើយ ស៊ីនយុនឃើញព្រះភក្ត្រព្រះនាងទល់ដែនដែលរលាកឆេះរលួយតាំងពីមុខរហូតដល់ប្រាណក្នុងសភាពគួរឱ្យខ្លាចពន់ពេក។

នាងគិតថា នឹងរត់ថយក្រោយទៅក្នុងព្រៃ ចាកចោលប្រាសាទនោះឆ្ពោះទៅកាន់ផ្លូវដែលនាងស្គាល់ តែស៊ីនយុនបានត្រឹមត្រហេបត្រហប ក្រោកមិនរួច ស្រែកមិនបានទើបសន្លប់ទន់ដៃឈងក្នុងគំនរទឹកកក។

ក្នុងអារម្មណ៍ចុងក្រោយ នាងគិតថានាងនឹងកកស្លាប់នៅក្នុងបរិវេណប្រាសាទខ្មោចនេះ។ មិនយូរប៉ុន្មាន សំឡេងមួយបានដាស់នាង គឺម៉ីហ្វួង៖

«ឯងក្រោកឡើង! ឯងក្រោកឡើងស៊ីនយុន»

នាងបើកភ្នែកព្រឹមៗប្រទះនឹងផ្ទឹមប្រសាទធំខ្មៅស្នឹល ខ្ពស់សន្លឹមដែលរុំព័ទ្ធទៅដោយពីងពាងនិងសម្បុកប្រជៀវ។ នាងស្រែកវាស ក្រោកឡើងឃើញខ្លួនឯងនៅដេកសន្លប់កណ្ដាលដំណាក់ចាស់បោះបង់ចោលមួយមិនមែនអ្វីដែលនាងធ្លាប់ឃើញទេ។

ពីចម្ងាយនាងឃើញខ្នងមិត្តនាងរត់ទៅ។

នាងរត់ទៅតាមផ្លូវនោះហើយស្រែកដង្ហោយ៖

«ម៉ីហ្វួង ម៉ីហ្វួង ឯងជួយខ្ញុំផង ខ្ញុំជិតស្លាប់ហើយ!»

ម៉ីហ្វួងមិនមាត់ នៅតែនាំផ្លូវនាងរត់ទៅមុខក្រវេចក្រវៀនរួចបាត់ស្រមោលមិត្តនាងសូន្យនៅក្បែរផ្លូវរទេះ។

ស្នូរសំឡេងកង់រទេះសេះបរមកពីចម្ងាយ។ ស៊ីនយុនត្រេកអរណាស់ នាងរត់ទៅប្រភពនោះ។

ទីបំផុតពិតជាមានរទេះសេះតូចមួយបោលមកពីចម្ងាយ នាងមិនស្គាល់គេទេ មិនមែនជារទេះដែលនាងធ្លាប់ជិះឡើយប៉ុន្តែមានមនុស្សប្រុសវ័យចំណាស់ជាអ្នកបញ្ជាសេះ។

គាត់ឃើញនាងនៅឈរកណ្ដាលផ្លូវញាក់ញ័រក៏ឈប់ជំនិះនឹងស្រែកគំហកសួរនាំ៖

«ឯងមកពីណា?»

«មកពីដំណាក់ខាងត្បូង!»

គាត់ភ្ញាក់ក្រញាងសម្លឹងរបៀបប្រុងតែផាយសេះ ស្រាប់តែនាងស្រែកឡើងបន្ត៖

«ជួយខ្ញុំផងពូអើយ!»

អ្នកបរទេះគាត់ធ្វើភ្នែកស្លើតស្លក់សម្លឹងទៅដំណាក់ខាងត្បូងដែលនៅឆ្ងាយពីចំហៀងក្រោយជួរព្រឹក្សាក្រាស់ ហើយបែរមកផ្ទង់សម្លឹងនាងពីលើដល់ក្រោមដូចជាខ្លាចថានាងមិនមែនជាមនុស្ស ប៉ុន្តែទាស់ត្រង់ថា ព្រះអាទិត្យបានឡើងឈរឡើងមកបំភ្លឺចិញ្ចាចទាំងព្រិលធ្លាក់ គាត់ឃើញដង្ហើមនាងដកអន្លើៗចេញជាចំហាយលើទឹកកក ទើបបានជាបុរសនោះមិនសង្ស័យច្រើនក៏ងក់ក្បាលបញ្ជា៖

«ឯងឆាប់ឡើងលើរទេះមក!»

នាងងក់ក្បាលហើយក៏តោងឡើង។

រទេះបោលចេញភ្លាមដោយមិនបង្អង់ទេ។ បានបន្តិចជនបរទេះសួរមកស៊ីនយុន៖

«ឯងឈ្មោះអ្វី អ្នកបម្រើដំណាក់ណាមួយ!»

ស៊ីនយុនប្រាប់ទាំងអស់នូវរឿងរ៉ាវដែលបានកើតឡើងដល់គាត់ និងរឿងដែលចៅហ្វាយស្រីរបស់នាងយកនាងមកឱ្យបម្រើព្រះនាងមកពីទល់ដែន។

«សូមពូជួយជូនខ្ញុំទៅអ្នកស្រីង៉ាវហានផង ខ្ញុំនឹងប្រាប់រឿងទាំងអស់ដល់គាត់!»

បុរសនោះហួសចិត្តជាខ្លាំងក៏ប្រាប់នាងវិញថា៖

«ឯងមិនដឹងទេ ប្រធានដំណាក់អ្នកបម្រើលោកស្រីង៉ាវហានត្រូវបានព្រះមហេសីដាក់ទោសឱ្យស្លាប់តាំងពីជិតមួយខែមុនម្ល៉េះ!»

ស៊ីនយុនភ្ញាក់ ភ័យជាខ្លាំង។

ពេលនោះហើយអ្នកបរទេសបានប្រាប់នាងថា អ្នកស្រីង៉ាវហានមានទោសក្នុងការជួញដូរអ្នកបម្រើទៅឱ្យពួកអ្នកម្នាងក្នុងវាំងជាថ្នូរនឹងមាសប្រាក់ ដូច្នេះហើយគាត់ក៏ត្រូវបានព្រះមហេសីកាត់ទោសស្លាប់ដោយឱ្យពួកអាមាត្យយកមកទម្លាក់ចោលក្នុងអណ្តូងសពធំមួយនៅព្រះរាជដំណាក់ខាងត្បូងរបស់អតីតស្នំសៀវ។

អ្នកបរទេសដែលអះអាងថាខ្លួនជាបងថ្លៃព្រះអង្គ និងជាបងប្រុសនៃស្នំឯកម្នាក់នៅដំណាក់ខាងក្រោយបានដឹងរឿងនេះ។ គាត់បាននាំនាងទៅជួបប្អូនស្រីដែលមានងារជាអ្នកម្នាងតឺយមានបុត្របីអង្គជាមួយព្រះអង្គ។

ម្នាងតឺយបានយល់ព្រមឱ្យស៊ីនយុនរស់នៅបម្រើចាប់ពីពេលនោះមក។

ប្រមាណបីខែក្រោយ ព្រះរាជាវិលមកពីទល់ដែនឆ្ងាយ។ ព្រះអង្គសួររកព្រះនាងដាកីមកពីនគរចំណុះភាគខាងជើងតែគ្មានអ្នកណាហ៊ាននិយាយរឿងនេះឡើយ គឺរឿងដែលមនុស្សទាំងបីនោះត្រូវបានគេបញ្ជូនទៅដំណាក់ខាងត្បូងយ៉ាងស្ងាត់កំបាំង។ ព្រះមហេសីបានទូលទ្រង់ថាពួកគេមកដល់មានសភាពទ្រុឌទ្រោមឆាយចង់បានប្រាសាទធំរស់នៅ បានជាត្រូវរៀបចំឱ្យទៅនៅដំណាក់ខាងត្បូង ពេលនេះបាត់ដំណឹងមិនដឹងរត់គេចទៅណាអស់។

តែដោយមានពួកស្នំឯកនិងអ្នកម្នាងខ្សឹបទូល ព្រះរាជាកើតការសង្ស័យក៏ហៅស៊ីនយុនចូលសួរនាំ។ ហេតុតែក្មេងស្មោះត្រង់ស៊ីនយុន បានប្រាប់រឿងទាំងអស់ដល់ទ្រង់៖

«ខ្ញុំម្ចាស់បានឃើញជាងមួយខែមុន រទេះសេះ៦មកឈប់នៅដំណាក់អ្នកម្នាងសៀវ ប៉ុន្តែពេលខ្ញុំម្ចាស់ត្រូវទៅបម្រើទ្រង់ ពួកគេបែរជាចេះហោះចេញពីក្នុងអណ្ដូង!»

ព្រះអង្គក៏បើកការស្រាវជ្រាវថ្មី។

ព្រះរាជាមិនដែលជឿលើមន្តអាគមឬខ្មោចព្រាយ ទើបទ្រង់បញ្ជាឱ្យដំណាក់ព្រហ្មទណ្ឌបើកការស្រាវជ្រាវថ្មី។ អណ្ដូងជាទីសង្ស័យនោះ ត្រូវបានគេរុករើ ហើយបានប្រទះឃើញសាកសពចាស់ថ្មីជាច្រើនដែលមិនបានរលួយព្រោះអាកាសធាតុត្រជាក់ខ្លាំង។

ក្នុងនោះមានទាំងម៉ីហួង អ្នកស្រីង៉ាវហាន និងមនុស្សមកពីទល់ដែនទាំងបីប្រាណផងដែរ។ ពេលនោះហើយស៊ីនយុនធ្លាក់ខ្លួនឈឺសឹងជ្រុះសក់ពេលដឹងថា គ្រប់គ្នាដែលនាងបានឃើញនៅដំណាក់ខាងត្បូងរួមទាំងម៉ីហួងមិត្តរបស់នាងផង សុទ្ធតែជាវិញ្ញាណខ្មោច។ ដោយសារការស៊ើបអង្កេតបានបង្ហាញថា ព្រះមហេសីជាអ្នកដុតក្រឡាបន្ទំសម្លាប់ព្រះនាងដាកី និងសម្លាប់បម្រើប្រុសស្រីទាំងពីរព្រមទាំងសម្លាប់អ្នកស្រីង៉ាវហានដែលដឹងរឿងទម្លាក់ក្នុងនោះ ព្រះរាជាបានសម្រេចទោសដកហូតតំណែង និងទម្លាក់ព្រះមហេសីទាំងរស់ទៅក្នុងអណ្ដូងដដែលជាការព្រមានដល់ស្នំឯកនិងបណ្ដាអ្នកម្នាងដទៃ។

ចាប់តាំងពីពេលនោះមកគ្មានអ្នកណាហ៊ានឆ្លងកាត់ព្រះរាជដំណាក់អណ្ដូងសពនោះទៀតទេ វាមិនមែនជាព្រះរាជដំណាក់ខាងត្បូងរបស់អ្នកម្នាងសៀវដ៏ប្រណីតទៀតឡើយ។ ស៊ីនយុនបានឆ្លៀតយកភួយរបស់នាងនិងម្ហូបទៅក្បែរផ្លូវជិតប្រសាទនោះហើយដុតបួងសួងឧទ្ទិសឱ្យបានដល់ម៉ីហួង។ យប់ដដែលនាងសុបិនឃើញម៉ីហួងដេកលើគ្រែក្នុងប្រសាទខាងត្បូងដោយកក់ក្ដៅ និងមានអាហារចម្អែតយ៉ាងសប្បាយចិត្ត។

រស់នៅក្នុងរាជវាំងបានរហូតដល់វ័យម្ភៃឆ្នាំ ដោយឃើញស៊ីនយុនជាមនុស្សមានភាពស្មោះត្រង់ធ្វើការធ្ងន់ធ្ងរមិនត្អូញ មិនថ្នាំងថ្នាក់ ឬមានគំនិតលោភលន់ អ្នកម្នាងតឺយ ដែលបានឡើងជាព្រះមហេសី បានប្រទានមង្គលការឱ្យស៊ីនយុនជាមួយនាយទាហានម្នាក់ដែលមានចិត្តថ្លើមល្អ។

ពេលចម្រើនវ័យទើបស៊ីនយុនបានដឹងការពិតថា ដំណាក់ខាងត្បូងគឺជាកន្លែងសម្រាប់បោះសម្លាប់ជាសម្ងាត់ក្រុមសត្រូវនៃព្រះមហេសីឬអ្នកណាក្តី ដែលមានសម្រស់ទើសមុខសម្រាប់ទ្រង់។

គេអាចសម្លាប់ដោយវិធីបង្កើតជាព័ត៌មានថា ស្នំឬនារីនោះឆ្លងជំងឺ ឬក៏កើតកូនមិនរួចដោយការចូលដៃនៃពួកមេដោះឬពួកយាយម៉ប្រក្នុងវាំង។

ចាប់តាំងពីព្រះមហេសីក៏ត្រូវទម្លាក់ទៅក្នុងអណ្តូងនេះ ក្រោយមកក្រុមអ្នកម្នាងផ្សេងៗទៀតសូម្បីតែរំឭកដល់ដំណាក់នោះក៏មិនហ៊ានដែរ។ រឿងដំណាក់មានអណ្តូងសពនេះត្រូវបានស៊ីនយុននិទានបន្តដល់ចៅៗរបស់នាងរហូតដល់ក្លាយជារឿងនិទានតគ្នាគួរឱ្យព្រឺព្រួច។